ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម
នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ
នៃប្រទេសជប៉ុន

# រឿងជោគជ័យនៃមុខរបរទីផ្សារជ្រូក
# សហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង



រៀបចំដោយ៖ គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

ឧបត្ថម្ភដោយ៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

ខែកក្កដា ឆ្នាំ២០១៥

រឿងជោគជ័យទី ១

**រឿងជោគជ័យទី ១**

**រឿងជោគជ័យនៃមុខរបរទីផ្សារជ្រូក**

**សហគមន៍សិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង**

បោះពុម្ពផ្សាយ៖ ខែកក្កដា ឆ្នាំ២០១៥

បោះពុម្ពដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម (MAFF)

គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

អស័យដ្ឋាន៖ # ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ប្រទេសកម្ពុជា

ទូរស័ព្ទ៖ (០២៣) ៨៨៣ ៤២៧ ទូរសារ៖ (០២៣) ៨៨៣ ៤២៧

© គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

# មាតិការ

សេចក្តីថ្លែងអំណរគុណ

I. សេចក្តីផ្តើម ........ ១

១. តើគម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញគឺជាអ្វី? ........ ១

២. គោលបំណងនៃការបោះពុម្ពរឿងជោគជ័យ ........ ១

៣. មូលហេតុនៃការជ្រើសរើសសហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង ........ ២

៤. និយមន័យនៃមុខរបរទីផ្សាររបស់សហគមន៍កសិកម្ម........ ២

II. រឿងជោគជ័យ ........ ៣

១. ប្រវត្តិរបស់សហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង........ ៣

២. សង្ខេបស្ថានភាពទូទៅរបស់សហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង ........ ៤

៣. ស្ថានភាពនៃមុខរបរទីផ្សារជ្រូកនៅក្នុងសហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង ........ ៥

៤. របៀបទំនាក់ទំនងរកឈ្មួញរបស់សហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង........ ៧

៥. របៀបកំណត់តម្លៃទិញជ្រូកសាច់ពីសមាជិក ........ ៧

៦. ផែនការនៅពេលអនាគត ........ ៨

# សេចក្តីថ្លែងអំណរគុណ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមថ្លែងអំណរគុណដល់សហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង និងសហការីទាំងអស់ ជាពិសេស លោក **នាង ចន្ថា** ប្រធានសហគមន៍កសិកម្មនេះដែលបានចំណាយពេលវេលាផ្តល់បទសំភាសន៍ និងព័ត៌មានដ៏មានតម្លៃដល់ក្រុមការងារនៃគម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញដើម្បីចងក្រងរឿងជោគជ័យនៃមុខរបរទីផ្សារជ្រូករបស់ "សហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង" ដែលជារឿងជោគជ័យទី១ នៃបណ្តារឿងជោគជ័យផ្សេងទៀត។

# I. សេចក្តីផ្តើម

## ១. តើគម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញគឺជាអ្វី?

ក្រោមការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុពីជំនួយផ្លូវការរបស់រដ្ឋាភិបាលជប៉ុន (Official Development Assistant, ODA) តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (Japan International Cooperation Agency, JICA) គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (Project for Establishing Business-oriented Agricultural Cooperative Models, BPAC) ត្រូវបានបង្កើត និងអនុវត្តដោយអគ្គនាយកដ្ឋានកសិកម្ម (General Directorate of Agriculture, GDA) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Ministry of Agriculture, Forestry and Fisheries, MAFF) ដែលសហការជាមួយអង្គការ JICA នៅកម្ពុជា។ គម្រោងកំពុងអនុវត្តនៅក្នុងខេត្តគោលដៅចំនួន៤ ដែលរួមមាន ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពង់ចាម និងខេត្តស្វាយរៀង សម្រាប់រយៈពេលប្រាំឆ្នាំ ដោយគិតចាប់ពីខែឧសភា ឆ្នាំ២០១៤ រហូតដល់ខែឧសភា ឆ្នាំ២០១៩។

គោលបំណងរួមនៃគម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញគឺដើម្បីផ្សព្វផ្សាយសហគមន៍កសិកម្មគំរូដែលប្រកបមុខរបរមានចែងនៅក្នុងច្បាប់ស្តីពីសហគមន៍កសិកម្មដូចជាមុខរបរឥណទាន មុខរបរផ្គត់ផ្គង់ និងមុខរបរទីផ្សារជាដើម ទៅដល់សហគមន៍កសិកម្មដទៃទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២. គោលបំណងនៃការបោះពុម្ពរឿងជោគជ័យ

គោលបំណងរបស់រឿងជោគជ័យនេះគឺដើម្បីស្វែងរកសហគមន៍កសិកម្មដែលមានភាពជោគជ័យលើការប្រកបមុខរបរនានាដូចជាមុខរបរទីផ្សារ ផ្គត់ផ្គង់ និងឥណទាន និងការអភិវឌ្ឍន៍រចនាសម្ព័ន្ធនិងការគ្រប់គ្រងរបស់សហគមន៍កសិកម្មនៅក្នុងប្រទេស ដើម្បីផ្សព្វផ្សាយព័ត៌មានទាំងនោះទៅដល់សហគមន៍សិកម្មផ្សេងទៀតសម្រាប់ប្រើប្រាស់ក្នុងការអភិវឌ្ឍន៍សហគមន៍កសិកម្មរបស់ខ្លួន ។

នេះគឺជារឿងជោគជ័យទី១របស់គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញដែលបានបោះពុម្ពផ្សព្វផ្សាយ។